ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងអប់រំ យុវជន និងកីឡា

# គោលនយោបាយ

# ស្តីពី

# កិច្ចការពារកុមារនៅសាលារៀន

កញ្ញា ២០១៦

# មាតិកា

**បុព្វកថា** .......... 3

**១. សេចក្តីផ្តើម** .......... 4

**២. ចក្ខុវិស័យ** .......... 6

**៣. គោលបំណង** .......... 6

**៤. គោលដៅ** .......... 6

**៥. យុទ្ធសាស្ត្រ** .......... 6

*៥.១ ការអនុវត្តក្របខ័ណ្ឌច្បាប់ និងយន្តការ* .......... 6

*៥.២ ការទប់ស្កាត់អំពើហិង្សាគ្រប់ទម្រង់លើកុមារ* .......... 7

*៥.៣. ការឆ្លើយតបទៅនឹងអំពើហិង្សាគ្រប់ទម្រង់លើកុមារ* .......... 7

*៥.៤. ការអប់រំនិងផ្សព្វផ្សាយព័ត៌មាន* .......... 8

*៥.៥. ការសម្របសម្រួល កិច្ចសហការ និងការលើកទឹកចិត្ត* .......... 8

*៥.៦ ការលើកកម្ពស់យេនឌ័រ* .......... 9

**៦. ផែនការសកម្មភាព** .......... 9

*៦.១ បង្កើតយន្តការ* .......... 9

*៦.២ បង្កើតក្របខណ្ឌគតិយុត្តិ* .......... 9

*៦.៣ គាំទ្រហិរញ្ញវត្ថុ* .......... 10

*៦.៤* ពង្រឹងសមត្ថភាពលើការការពារកុមារ .......... 10

*៦.៥ ដំណើរការអនុវត្តគម្រោង* .......... 10

**៧. ការតាមដាន និងវាយតម្លៃ** .......... 10

**៨. សន្និដ្ឋាន** .......... 11

# បុព្វកថា

ក្រសួងអប់រំ យុវជន និងកីឡាបានកសាងគោលនយោបាយស្តីពីកិច្ចការពារកុមារនៅសាលារៀននេះដែលកំណត់ពីក្របខណ្ឌទូលំទូលាយ សំដៅធានាឱ្យកុមារគ្រប់រូបទទួលបាននូវការការពារនៅតាមគ្រឹះស្ថានសិក្សាសាធារណៈ និងឯកជន ព្រមទាំងទទួលបាននូវបរិយាកាសរៀនសូត្រប្រកបដោយភាពកក់ក្តៅ និងសុវត្ថិភាព។

គោលនយោបាយនេះគាំទ្រដល់សិទ្ធិទទួលបានការអប់រំរបស់កុមារគ្រប់រូប ដោយពុំមានផលប៉ះពាល់ដល់ផ្លូវកាយ និងផ្លូវចិត្តអ្វីឡើយ។ កុមារនឹងទទួលបានការការពារពីទង្វើទាំងឡាយដែលនាំឱ្យមានផលប៉ះពាល់ជាអវិជ្ជមានដល់ឱកាសទទួលបានការអប់រំ សុខភាព និងសុខុមាលភាពរបស់ពួកគេ ព្រមទាំងទទួលបាននូវការគោរពនូវសេចក្តីថ្លៃថ្នូរនិងសេរីភាពរួចផុតពីទណ្ឌកម្មផ្សេងៗគ្រប់ទម្រង់។ គោលនយោបាយនេះក៏ផ្តល់ឱកាសដល់ការអភិវឌ្ឍសាលារៀន ឱ្យក្លាយជាទីកន្លែងមានសុវត្ថិភាពសម្រាប់កុមារ ដើម្បីទប់ស្កាត់អំពើហិង្សា និងគ្រោះថ្នាក់គ្រប់រូបភាពដែលកើតឡើងចំពោះកុមារ និងកំណត់ពីបញ្ហាប្រឈម ផ្តល់ការពង្រឹងសេវា ថែរក្សាសុវត្ថិភាពផ្ទាល់ខ្លួន និងជួយផ្តល់ការគាំទ្រដល់កុមារដែលជួបប្រទះគ្រោះថ្នាក់ និងមានការរើសអើង។ សាលារៀន និងសហគមន៍ត្រូវការការគាំទ្រ និងលើកទឹកចិត្តឱ្យធ្វើការងារជាមួយគ្នា ដោយសហការជាមួយគ្រប់អ្នកពាក់ព័ន្ធដើម្បីកសាងនូវប្រព័ន្ធការពារកុមារមួយប្រកបដោយប្រសិទ្ធភាពខ្ពស់។

ក្រសួងអប់រំ យុវជន និងកីឡាសង្ឃឹម និងជឿជាក់ថា គោលនយោបាយស្តីពីកិច្ចការការពារកុមារនៅសាលារៀននេះ នឹងផ្តល់កាលានុវត្តភាពឱ្យកុមារទាំងអស់ទទួលបាននូវសិទ្ធិការពារគ្រប់ៗរូប ដើម្បីឱ្យគេក្លាយខ្លួនជាសមាជិកសកម្មរស់នៅក្នុងសង្គមប្រកបដោយប្រសិទ្ធភាព និងទទួលបានជោគជ័យ។ ក្រសួងអប់រំ យុវជននិងកីឡាសូមថ្លែងអំណរគុណដល់ក្រសួង ស្ថាប័ន និងដៃគូអភិវឌ្ឍនានា ដែលកំពុងជួយគាំទ្រវិស័យអប់រំនៅកម្ពុជានិងបន្តចូលរួមសហការផ្តល់សេវា និងបច្ចេកទេស ព្រមទាំងលើកកម្ពស់គុណភាពអប់រំឱ្យកាន់តែល្អប្រសើរ ជាពិសេសលើកិច្ចការពារសិទ្ធិកុមារនៅក្នុងសាលារៀន។

ភ្នំពេញ ថ្ងៃទី ១៥ ខែកញ្ញា ឆ្នាំ២០១៦

រដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និងកីឡា

បណ្ឌិត ហង់ ជួន ណារ៉ុន

# ១. សេចក្តីផ្តើម

អំពើហិង្សាលើកុមារ [1] គឺជាបញ្ហាសិទ្ធិមនុស្ស សង្គម និងសុខភាពសាធារណៈមួយដ៏ធ្ងន់ធ្ងរនៅបណ្តាប្រទេសលើសកលលោក ហើយផលវិបាកនៃអំពើហិង្សានេះអាចបង្កគ្រោះថ្នាក់ចំពោះប្រទេសនោះ។ ម្យ៉ាងទៀត ពុំមានប្រទេសណាមួយដែលអាចគេចផុតពីផលវិបាកនេះបានឡើយ ទោះបីជាប្រទេសអ្នកមាន ឬប្រទេសក្រីក្រក៏ដោយ។ អំពើហិង្សាធ្វើឱ្យចុះខ្សោយនូវគ្រឹះដ៏រឹងមាំដែលកុមារត្រូវការ ដើម្បីរស់រានមានជីវិតប្រកបដោយសុខុមាលភាព និងផលិតភាពខ្ពស់ ព្រមទាំងធ្វើឱ្យមានការរំលោភបំពាន ទៅលើសិទ្ធិមូលដ្ឋានរបស់កុមារ ក្នុងការទទួលបានកុមារភាពប្រកបដោយសុវត្ថិភាព។ កុមារគ្រប់រូបមានសិទ្ធិក្នុងការទទួលបានការសិក្សាអប់រំ និងការការពារ ដូចមានចែងក្នុងអនុសញ្ញា អ.ស.ប ស្តីពីសិទ្ធិកុមារ មាត្រា២ កថាខ័ណ្ឌ២ "រដ្ឋភាគីត្រូវប្រកាន់យកវិធានការសមស្របទាំងឡាយ ដើម្បីធានាថា កុមារត្រូវបានការពារ តទល់នឹងរាល់ទម្រង់នៃការរើសអើង ឬការដាក់ទណ្ឌកម្ម ដោយផ្អែកលើស្ថានភាព សកម្មភាព ការបញ្ចេញមតិ..." មាត្រា២៨ "រដ្ឋភាគីទទួលស្គាល់សិទ្ធិរបស់កុមារ ក្នុងការទទួលបាននូវការអប់រំ...និងដោយឈរលើមូលដ្ឋាននៃលទ្ធភាពស្មើគ្នា..." មាត្រា៣៦ "រដ្ឋភាគីត្រូវការពារ កុមារតទល់នឹងរាល់ទម្រង់ផ្សេងទៀតនៃការជិះជាន់ ដែលប៉ះពាល់ដល់គ្រប់ទិដ្ឋភាពនៃ ផាសុកភាពរបស់កុមារ"។

ប្រជាជនកម្ពុជាមួយភាគធំជាកុមារ ដោយក្នុងនោះប្រជាជន៣៥%មានអាយុតិចជាង ១៥ឆ្នាំ។ ជាការគួរឱ្យសោកស្តាយ អំពើហិង្សាលើកុមារកម្ពុជានៅមានកម្រិតខ្ពស់ ហើយផ្តល់ផលវិបាកយ៉ាងច្រើនដល់ពួកគេ និងប្រទេសជាតិទាំងមូល។ របាយការណ៍របកគំហើញនៃការសិក្សាស្រាវជ្រាវស្តីពីអំពើហិង្សាលើកុមារក្នុងប្រទេសកម្ពុជា ឆ្នាំ២០១៣របស់អង្គការយូនីសេហ្វ បានបង្ហាញថា កុមារច្រើនជាង៥០%ទទួលរងអំពើហិង្សាផ្នែករាងកាយ ២៥%ទទួលរងការរំលោភបំពានផ្នែកផ្លូវចិត្ត ហើយប្រហែលជា៥%ទទួលរងការរំលោភបំពានផ្លូវភេទ។

អំពើហិង្សាលើកុមារ ផ្តល់ផលប៉ះពាល់ដល់ការអភិវឌ្ឍរបស់កុមារពេញមួយជីវិតរបស់គេ។ បន្ថែមពីលើផលប៉ះពាល់រយៈពេលខ្លី ដូចជា រងរបួសរាងកាយនិងផ្លូវចិត្ត ការធ្លាប់រងនូវអំពើហិង្សាតាំងពីវ័យនៅកុមារ ជាកត្តាមួយធ្វើឱ្យពួកគេក្លាយជាមនុស្សពេញវ័យ ដែលមាន

---

[1] យោងតាមមាត្រា១៩នៃអនុសញ្ញាស្តីពីសិទ្ធិកុមារ **ទម្រង់នៃអំពើហិង្សាលើកុមារ** សំដៅលើ ការធ្វើឲ្យរបួស ឬការរំលោភបំពានលើរាងកាយ ឬ លើផ្លូវចិត្ត ការទុកចោលមិនយកចិត្តទុកដាក់ ឬការមិនអើពើ ការធ្វើបាប ឬការកេងប្រវ័ញ្ច រួមទាំងការរំលោភបំពានផ្លូវភេទ។

បញ្ហាមួយចំនួនខាងអាកប្បកិរិយា និងផ្លូវចិត្ត។ ការរងនូវអំពើហិង្សាអាចបណ្តាលឱ្យមានការរើសអើងប្រឆាំងនឹងកុមារនិងគ្រួសាររបស់គេនៅក្នុងសង្គម ជាពិសេសនៅក្នុងករណីអំពើហិង្សាលើផ្លូវភេទ។ អំពើហិង្សានាំមកនូវផលវិបាកយ៉ាងធ្ងន់ធ្ងរចំពោះកុមារម្នាក់ៗ និងគ្រួសារគេ ចំពោះសហគមន៍ និងចុងក្រោយចំពោះសង្គមជាតិទាំងមូល។

ឆ្លើយតបទៅនឹងបញ្ហាប្រឈមខាងលើ រាជរដ្ឋាភិបាលបានដាក់ចេញនូវការប្តេជ្ញាចិត្តនានាក្នុងការទប់ស្កាត់ និងឆ្លើយតបទៅនឹងអំពើហិង្សាលើកុមារ និងបានកសាងផែនការជាតិសម្រាប់អភិវឌ្ឍន៍កុមារ២០១៦-២០១៨ ផែនការសកម្មភាពជាតិលុបបំបាត់អំពើហិង្សាលើកុមារនៅកម្ពុជា។ល។ ជាមួយគ្នានេះផងដែរ ក្រសួងអប់រំ យុវជន និងកីឡា ប្តេជ្ញាថានឹងបញ្ចូលការអប់រំអំពីភាពជាឪពុកបែបវិជ្ជមាន ពង្រឹងការអនុវត្តច្បាប់អប់រំដើម្បីធានាថា បុគ្គលិកសិក្សាទាំងអស់ប្រកាន់ខ្ជាប់នូវក្រមសីលធម៌គ្រូបង្រៀន ដាក់វិន័យចំពោះបទល្មើសព្រហ្មទណ្ឌនិងការល្មើសក្រមសីលធម៌គ្រូបង្រៀន ជាពិសេស ការរំលោភបំពានផ្លូវភេទ។ ក្រសួងក៏ជំរុញការអនុវត្តវិធីសាស្ត្ររៀននិងបង្រៀនដោយអហិង្សា បង្កើតយន្តការរាយការណ៍និងទទួលបណ្តឹងតវ៉ាពីការរំលោពបំពានប្រកបដោយប្រសិទ្ធភាព មានលក្ខណៈកុមារមេត្រី និងសមស្របសម្រាប់កុមារីនៅគ្រប់សាលារៀន។ល។

គោលនយោបាយស្តីពីកិច្ចការពារកុមារនៅសាលារៀន មានគោលបំណងជំរុញលើកកម្ពស់ ឱ្យមានការបង្កើតនូវបរិយាកាសរៀនសូត្រប្រកបដោយសុវត្ថិភាព សុខុមាលភាព និងផ្តល់ការគាំទ្រដល់កុមារគ្រប់រូបដែលកំពុងរៀននៅតាមគ្រឹះស្ថានសិក្សាសាធារណៈ និងឯកជន។ វាជាឯកសារមួយលើកកម្ពស់ការប្តេជ្ញាចិត្ត និងការចូលរួមរបស់សហគមន៍ ដើម្បីផ្តល់ការការពារដល់កុមារ ស្របតាមច្បាប់នៃព្រះរាជាណាចក្រកម្ពុជាក្នុងការការពារ និងលើកកម្ពស់សិទ្ធិកុមារ ក៏ដូចជាអភិក្រម ឬវិធីសាស្ត្រការពារកុមារនៅថ្នាក់ជាតិ និងថ្នាក់អន្តរជាតិ ហើយផ្តោតសំខាន់លើយុទ្ធសាស្ត្រទប់ស្កាត់ជាមុនសម្រាប់អន្តរាគមន៍ទាន់ពេលវេលា ដើម្បីគាំទ្រដល់កុមារដែលរងគ្រោះពីការរំលោភបំពាននានា និងកុមារដែលកំពុងប្រឈមនឹងហានិភ័យ។ គោលនយោបាយនេះក៏មានតួនាទីសំខាន់សម្រាប់ឱ្យសាលារៀនកាត់បន្ថយ ការរំលោភបំពានលើកុមារ ការកេងប្រវ័ញ្ច ការមិនអើពើចំពោះកុមារ និងការទទួលខុសត្រូវដែលមានចំពោះកុមារ។ លើសពីនេះកុមារមានសិទ្ធិទទួលបានបរិយាកាសរៀនសូត្រមួយប្រកបដោយសុវត្ថិភាព និងពុំមានអំពើហិង្សា។ វាជំរុញមិនឱ្យមានការអត់ឱនចំពោះអំពើហិង្សា ការរំលោភបំពានការកេងប្រវ័ញ្ច និងការមិនអើពើចំពោះកុមារឡើយ។

គោលនយោបាយនេះត្រូវបានអនុវត្តចំពោះកុមារគ្រប់រូប ដោយមិនប្រកាន់ភេទ ពិការភាព ជាតិពន្ធ ជំនឿ សាសនា ឬនិន្នាការណាមួយឡើយ និងគោរពគោលការណ៍នៃការរក្សាការសម្ងាត់ ជីវភាពឯកជន សំឡេងនិងការចូលរួមរបស់កុមារ។

## ២. ចក្ខុវិស័យ

កុមារគ្រប់រូបទទួលបានការលូតលាស់ទាំងផ្លូវកាយ ផ្លូវចិត្ត បញ្ញា និងស្មារតី ដោយគ្មានអំពើហិង្សាគ្រប់ទម្រង់ ដើម្បីឱ្យក្លាយជាធនធានមនុស្ស សម្រាប់អភិវឌ្ឍន៍ប្រទេសប្រកបដោយចេរភាព។

## ៣. គោលបំណង

អភិវឌ្ឍប្រព័ន្ធនិងយន្តការការពារកុមារ និងសុខុមាលភាពកុមារ ដោយធានាថា គ្រឹះស្ថានសិក្សាសាធារណៈ (ទាំងក្នុងនិងក្រៅប្រព័ន្ធ) និងឯកជនជាកន្លែងដែលមានសុវត្ថិភាពពីគ្រប់ទម្រង់នៃអំពើហិង្សាលើកុមារ។

## ៤. គោលដៅ

- ធានាថាសាលារៀន(សាធារណៈនិងឯកជន)ទាំងអស់ ជាកន្លែងដែលមានសុវត្ថិភាពដល់កុមារគ្រប់រូប ជាពិសេសកុមារពិការ កុមារកំព្រា និងក្រុមកុមារងាយរងគ្រោះដទៃទៀត។
- បញ្ជ្រាប និងពង្រឹងតួនាទីនិងការទទួលខុសត្រូវ លើកិច្ចការពារកុមារទៅក្នុងយន្តការឬបណ្តាញដែលមានស្រាប់ ដូចជា គណៈកម្មាធិការទ្រទ្រង់សាលារៀន ក្រុមប្រឹក្សាកុមារ ហើយបង្កើនកិច្ចសម្របសម្រួលរវាងយន្តការនិងបណ្តាញទាំងនេះជាមួយ គណៈកម្មាធិការទទួលបន្ទុកកិច្ចការនារី និងកុមារឃុំ/សង្កាត់។
- ពង្រឹងប្រសិទ្ធភាពនៃការអនុវត្តច្បាប់និងលិខិតបទដ្ឋានគតិយុត្តិលើការការពារកុមារ។
- បង្កើនការយល់ដឹងអំពីកិច្ចការពារកុមារ ដល់បុគ្គលិកអប់រំ សហគមន៍ និងអ្នកពាក់ព័ន្ធ។
- បង្កើនកិច្ចសហការរវាងក្រសួង មន្ទីរ ការិយាល័យអប់រំ យុវជន និងកីឡា និងស្ថាប័នពាក់ព័ន្ធ ដើម្បីដោះស្រាយបញ្ហាដែលទាក់ទងនឹងការការពារ និងអភិវឌ្ឍកុមារ។

## ៥. យុទ្ធសាស្ត្រ

### *៥.១ ការអភិវឌ្ឍក្របខ័ណ្ឌច្បាប់ និងយន្តការ*

- រៀបចំលិខិតបទដ្ឋាននិងយន្តការផ្សេងៗ ដើម្បីឱ្យកុមារគ្រប់រូបនៅក្នុងសាលារៀនទទួលបានការការពារពេញលេញ តាមផ្លូវច្បាប់ និងទទួលបានជំនួយគាំពារគ្រប់រូបភាព ដើម្បីធានាថាកុមារជៀសផុតពីគ្រោះថ្នាក់បន្ថែមទៀតនិងទទួលបានការសះស្បើយឡើងវិញ

- លើកកម្ពស់និងពន្លឿនការអនុវត្តគោលនយោបាយក្របខណ្ឌច្បាប់ យន្តការពាក់ព័ន្ធដែលមានស្រាប់ និងយន្តការថ្មី
- កសាងផែនការសកម្មភាពដោយកំណត់នូវសូចនាករ សកម្មភាពជាក់លាក់ ក្របខ័ណ្ឌពេលវេលា ធនធាន និងការទទួលខុសត្រូវ
- គោលនយោបាយការពារកុមារនៅសាលារៀននេះ នឹងត្រូវបានត្រួតពិនិត្យឡើងវិញក្នុងរយៈពេលជាក់លាក់ ដើម្បីឆ្លុះបញ្ចាំងនូវការផ្លាស់ប្តូររបស់សង្គម ពាក់ព័ន្ធនឹងកិច្ចការពារកុមារ។

## *៩.២ ការទប់ស្កាត់អំពើហិង្សាគ្រប់ទម្រង់លើកុមារ*

- បង្កើតនូវបរិស្ថានសិក្សាបើកចំហ[2] សម្រាប់កុមារគ្រប់រូប ជាពិសេសត្រូវកំណត់នូវអ្វីដែលសាលារៀន បុគ្គលិកអប់រំ និងអ្នកពាក់ព័ន្ធ គួរធ្វើនិងមិនគួរធ្វើ ក្នុងការបង្កើតបរិស្ថានសិក្សាបើកចំហនេះ
- ទប់ស្កាត់រាល់ទម្រង់បង្កការរងគ្រោះដល់កុមារ តាមរយៈការធ្វេសប្រហែសឬសកម្មភាពឥរិយាបថអវិជ្ជមានរបស់អ្នកពាក់ព័ន្ធក្នុងសាលារៀន
- លើកកម្ពស់ការយល់ដឹងអំពីសិទ្ធិកុមារ ទម្រង់នានានៃអំពើហិង្សាលើកុមារ និងការអប់រំវិន័យបែបវិជ្ជមានដល់គ្រប់អ្នកពាក់ព័ន្ធ ដល់គ្រូនិងបុគ្គលិកសាលារៀនជាចាំបាច់
- រៀបចំនីតិវិធីរដ្ឋបាលសម្រាប់ភ្ញៀវចេញចូលក្នុងសាលារៀន ដើម្បីពង្រឹងសុវត្ថិភាពសម្រាប់កុមារ
- ពង្រឹងនីតិវិធីក្នុងការជ្រើសរើសបុគ្គលិកបម្រើការនៅក្នុងសាលារៀន ដោយធានាថា គ្រូដែលធ្លាប់បានព្យួរឬបណ្តេញចេញ និងទទួលការព្រមានឬចោទប្រកាន់ត្រូវបានកត់ត្រាទុកក្នុងបញ្ជីព័ត៌មាន ដើម្បីចៀសវាងកុំឱ្យមានការជ្រើសរើសគ្រូដដែលមកបម្រើការងារជាគ្រូបង្រៀន ឡើងវិញដោយស្ថាប័នផ្សេងទៀត។

## *៩.៣. ការឆ្លើយតបទៅនឹងអំពើហិង្សាគ្រប់ទម្រង់លើកុមារ*

- រៀបចំយន្តការនិងប្រព័ន្ធរាយការណ៍អំពីករណីផ្សេងៗ កើតមានលើកុមារ ហើយដែលកុមារងាយទទួលយកបាន មានលក្ខណៈកុមារមេត្រី និងផ្តោតទៅលើយេនឌ័រ
- កំណត់នីតិវិធីរាយការណ៍ និងសមត្ថកិច្ចណាមានអំណាចក្នុងការព្យួរ ឬបណ្តេញចេញគ្រូបង្រៀនណាម្នាក់ដែលបានប្រព្រឹត្តខុស

---

[2] លក្ខខណ្ឌនៃបរិស្ថានសិក្សាបើកចំហនឹងត្រូវកំណត់ដោយឯកសារគាំទ្រការអនុវត្ត

- រៀបចំឱ្យមានសេវាគាំទ្រផ្សេងៗ ដើម្បីធានាឱ្យមានការគោរពឯកជនភាព ការរក្សាការសម្ងាត់ និងសុវត្ថិភាពចំពោះកុមាររងគ្រោះ
- ស្វែងរកដំណោះស្រាយនានា នៅពេលមានផលប៉ះពាល់លើសុខុមាលភាពខាងផ្លូវកាយ ផ្លូវចិត្ត/អារម្មណ៍របស់កុមារ
- ធានាឱ្យបានថាបុគ្គលិក/បុគ្គលដែលបានប្រព្រឹត្តិបទល្មើសត្រូវបានដាក់ទណ្ឌកម្មទៅតាមច្បាប់ជាធរមាន
- បង្កើតប្រព័ន្ធតាមដានករណីនិងបុគ្គលដែលបានរំលោភបំពានលើកុមារ។

## ៥.៤. ការអប់រំនិងផ្សព្វផ្សាយព័ត៌មាន

- កសាងឯកសារព័ត៌មានពាក់ព័ន្ធ ការការពារ ការរំលោភបំពានលើកុមារ
- ផ្សព្វផ្សាយឯកសារ និងសកម្មភាពទប់ស្កាត់ការរំលោភបំពាន លើកុមារតាមគ្រប់ទម្រង់ដល់សាលារៀន សហគមន៍ មាតាបិតា ឬអ្នកអាណាព្យាបាល អាជ្ញាធរមូលដ្ឋាន និងអ្នកពាក់ព័ន្ធ ដោយបញ្ជ្រាបការយល់ដឹងពីកិច្ចការពារកុមារនៅក្នុងកម្មវិធីសិក្សា ផែនការនិងគោលនយោបាយពាក់ព័ន្ធនានា
- ផ្សព្វផ្សាយអំពីការអប់រំវិន័យបែបវិជ្ជមានដល់បុគ្គលិកអប់រំ និងមាតាបិតា ឬអាណាព្យាបាល
- សហការជាមួយអាជ្ញាធរនិងអ្នកពាក់ព័ន្ធនានា ដើម្បីផ្សព្វផ្សាយច្បាប់និងកម្រិតទោសទណ្ឌស្តីពីការរំលោភលើសិទ្ធិកុមារឱ្យបានទូលំទូលាយ និងលើកជាករណីសិក្សាមកចាក់បញ្ចាំង តាមប្រពន្ធផ្សព្វផ្សាយដល់សាធារណៈជនឱ្យបានដឹងនិងឃើញ។

## ៥.៥. ការសម្របសម្រួល កិច្ចសហការ និងការលើកទឹកចិត្ត

- ពង្រឹងកិច្ចសហការរវាងបុគ្គលិកអប់រំជាមួយមាតាបិតាឬអ្នកអាណាព្យាបាល សហគមន៍ អាជ្ញាធរមានសមត្ថកិច្ច និងការចូលរួមពីស្ថាប័នពាក់ព័ន្ធនានា ដើម្បីគាំទ្រ ការការពារកុមារ
- ជំរុញបុគ្គលិកអប់រំគ្រប់រូប ត្រូវចូលរួមនិងទទួលខុសត្រូវ ក្នុងការទប់ស្កាត់ការរំលោភបំពានកុមារ
- សម្របសម្រួលឱ្យមានការចូលរួមនិងសហការពីដៃគូអភិវឌ្ឍ និងអង្គការសង្គមស៊ីវិលនានា ក្នុងការអនុវត្តគោលនយោបាយនេះ
- ផ្តល់ការលើកទឹកចិត្តដល់បុគ្គលិកអប់រំឆ្នើម ដែលបានចូលរួមយ៉ាងសកម្មទប់ស្កាត់ការរំលោភបំពានលើកុមារ។

### ៥.៦ ការលើកកម្ពស់យេនឌ័រ

- ធានាឱ្យមានការបង្ការនិងការការពារកុមារពីអំពើហិង្សា ជាពិសេសអំពើហិង្សាលើកុមារី
- ផ្តល់កាលានុវត្តភាពដល់កុមារីឬស្ត្រី ក្នុងការចូលរួមជាគណៈកម្មការការពារកុមារ
- លប់បំបាត់ការរើសអើងចំពោះកុមាររងគ្រោះ ជាពិសេសកុមារី
- លើកកម្ពស់ឱ្យមានការចូលរួមរបស់កុមារី ក្នុងសកម្មភាពទប់ស្កាត់ការរំលោភបំពានលើកុមារ ជាពិសេសកុមារីដែលងាយរងគ្រោះ។

## ៦. ផែនការសកម្មភាព

ដើម្បីអនុវត្តគោលនយោបាយស្តីពីកិច្ចការពារកុមារនៅសាលារៀននេះ ឱ្យមានប្រសិទ្ធភាពខ្ពស់ ចាំបាច់ត្រូវមានផែនការសកម្មភាព ដើម្បីអនុវត្តនៅគ្រប់គ្រឹះស្ថានសិក្សាសាធារណៈ និងឯកជនដូចខាងក្រោម៖

### ៦.១ បង្កើតយន្តការ

- បង្កើតគណៈកម្មការការពារកុមារក្នុងវិស័យអប់រំនៅកម្រិតជាតិ រាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ
- កំណត់ការទទួលខុសត្រូវក្នុងការអនុវត្តគោលនយោបាយនេះ ជាពិសេស ការទទួលខុសត្រូវរបស់នាយកដ្ឋានពាក់ព័ន្ធគ្រប់កម្រិតរបស់ក្រសួងអប់រំ
- បង្កើតក្រុមបង្គោលការពារកុមារនៅកម្រិតសាលារៀន ទទួលបន្ទុកទទួលពាក្យបណ្តឹងតវ៉ា និងដោះស្រាយរាល់កង្វល់និងបញ្ហា
- ធានាឱ្យយន្តការការពារអនុវត្តមុខងារប្រកបដោយប្រសិទ្ធភាព ពង្រឹងការប្រមូល និងគ្រប់គ្រងទិន្នន័យពាក់ព័ន្ធនឹងករណីនាំការរំលោភបំពានលើកុមារ និងការការពារកុមារ។
- ធ្វើរបាយការណ៍អំពីចំនួនករណី (ទោះមានឬមិនមានកើតឡើងក្តី) តាមកម្រិតសាលារៀន និងផ្សព្វផ្សាយជាប្រចាំខែ ជាទូលំទូលាយដល់អ្នកពាក់ព័ន្ធ។

### ៦.២ បង្កើតក្របខណ្ឌគតិយុត្តិ

- កសាងគោលការណ៍ណែនាំនានាដើម្បីជួយគាំទ្រការអនុវត្តកិច្ចការពារកុមារនៅសាលារៀន
- រៀបចំប្រកាសស្តីពីគណៈកម្មការការពារកុមារក្នុងវិស័យអប់រំ នៅថ្នាក់ជាតិនិងថ្នាក់ក្រោមជាតិ

- រៀបចំក្របខណ្ឌការងារកិច្ចការពារកុមារ ដូចជា របៀបរាយការណ៍ពីករណីហិង្សាលើកុមារ ការគ្រប់គ្រងករណី។ល។

### ៦.៣ គាំទ្រហិរញ្ញវត្ថុ

- គ្រប់អ្នកពាក់ព័ន្ធអាចប្រើប្រាស់ថវិការបស់ក្រសួងអប់រំ យុវជន និងកីឡា មួយផ្នែកនៃថវិកាអភិវឌ្ឍន៍សាលារៀនប្រចាំឆ្នាំ និងថវិកាដែលបានមកពីប្រភពផ្សេងទៀត
- ជំរុញលើកទឹកចិត្តដៃគូអភិវឌ្ឍជាតិ និងអន្តរជាតិដែលធ្វើការងារជាមួយក្រសួងអប់រំ យុវជន និងកីឡា បែងចែកធនធានរបស់ខ្លួនដើម្បីគាំទ្រការអនុវត្តគោលនយោបាយនេះ។

### ៦.៤ ពង្រឹងសមត្ថភាពលើការការពារកុមារ

- កសាងឯកសារគាំទ្រការអនុវត្ត និងការបណ្ដុះបណ្ដាល ដោយសហការជាមួយដៃគូអភិវឌ្ឍ និងសាលារៀន
- បំប៉នសមត្ថភាពដល់ក្រុមគ្រូបង្គោលថ្នាក់ជាតិ ក្រុមបំប៉ន និងពិនិត្យតាមដានថ្នាក់ក្រុងស្រុក ខណ្ឌ គ្រូបង្រៀន សិស្សានុសិស្ស និងអ្នកពាក់ព័ន្ធផ្សេងទៀត។

### ៦.៥ ដំណើរការអនុវត្តគម្រោង

រៀបចំផែនការអនុវត្តគោលនយោបាយស្ដីពីកិច្ចការពារកុមារនៅសាលារៀន រយៈពេលមធ្យម និងវែង ដោយមានការចូលរួមពីគ្រប់ដៃគូពាក់ព័ន្ធ ជាពិសេសសិស្ស/កុមារ ដើម្បីធានាប្រសិទ្ធភាព និងនិរន្តភាព។ ផែនការនេះត្រូវបង្ហាញពីចក្ខុវិស័យរបស់ក្រសួងអប់រំ យុវជននិងកីឡា ក្នុងការអនុវត្តគោលនយោបាយនេះ និងឆ្លើយតបទៅនឹងផែនការយុទ្ធសាស្ត្រវិស័យអប់រំ។

## ៧. ការតាមដាន និងវាយតម្លៃ

ដើម្បីឱ្យគោលនយោបាយនេះ មានវិសាលភាពក្នុងការអនុវត្តកិច្ចការពារកុមារនៅសាលារៀន ចាំបាច់ត្រូវមានប្រព័ន្ធតាមដាន និងវាយតម្លៃ ដោយផ្ដោតលើ ៖

- ចំណុចដៅ និងយុទ្ធសាស្ត្រនៃគោលនយោបាយស្ដីពីការការពារកុមារនៅសាលារៀន
- សូចនាករនៃផែនការស្ដីពីការការពារកុមារនៅសាលារៀន
- ការចូលរួមរបស់គណៈកម្មការ ក្រុមបង្គោល និងសហគមន៍
- សុវត្ថិភាព និងបរិស្ថានសិក្សារបស់កុមារ នៅតាមសាលារៀនមានភាពប្រសើរឡើងដែលបានមកពីការអនុវត្តគោលនយោបាយ
- លទ្ធផលដែលទទួលបាន ធៀបទៅនឹងចំណុចដៅ។

# ៨. សន្និដ្ឋាន

គោលនយោបាយស្តីពីកិច្ចការពារកុមារនៅសាលារៀននេះ ដើរតួនាទីយ៉ាងសំខាន់ក្នុងការជួយលើកស្ទួយ និងគាំទ្រកុមារឱ្យទទួលបានសិទ្ធិ ព្រមទាំងផលប្រយោជន៍ទាំងឡាយដែលមានចែងក្នុងរដ្ឋធម្មនុញ្ញជាតិ និងអនុសញ្ញាអន្តរជាតិនានា ដែលធានាកុមារឱ្យជៀសផុតពីអំពើហិង្សាគ្រប់ទម្រង់ ធ្វើឱ្យសាលារៀនក្លាយជាកន្លែងមានសុវត្ថិភាព ហើយកុមារអាចទទួលបានលទ្ធផលល្អប្រសើរក្នុងការសិក្សា។

ក្រសួងសង្ឃឹមនិងជឿជាក់ថា អង្គភាពអ្នកពាក់ព័ន្ធ និងដៃគូអភិវឌ្ឍ នឹងចូលរួមយ៉ាងសកម្ម ក្នុងការបណ្តុះបណ្តាល ផ្សព្វផ្សាយ អនុវត្ត ពិនិត្យតាមដាននិងវាយតម្លៃ រួមចំណែកដោះស្រាយបញ្ហា និងធ្វើអន្តរាគមន៍ ដើម្បីទទួលបានជោគជ័យលើការអនុវត្តគោលនយោបាយនេះ។